ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៣ ស ហវ.ប្រក

# ប្រកាស

## ស្តីពីការបង្កើត និងតែងតាំងមន្ត្រីនៃ
## លេខាធិការដ្ឋានគ្រួមប្រឹក្សាមូលនិធិឃុំសង្កាត់

********

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៦/អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិ ឃុំ សង្កាត់
- បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ សង្កាត់ ស្ថិតក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមមាត្រា ៦ នៃអនុក្រឹត្យលេខ ១៦ អនក្រ. បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ ។

**ប្រការ ២ :** ត្រូវបានតែងតាំងមន្ត្រីទទួលបន្ទុកការងារលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលមូលនិធិឃុំសង្កាត់ ដែលមានរាយនាមដូចខាងក្រោមនេះ ៖

១- លោក ចាន់ ធី ប្រធានការិយាល័យគោលនយោបាយនិងផែនការនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ជាលេខាធិការប្រចាំការអចិន្ត្រៃយ៍

២- លោក ហ៊ាន់ វណ្ណារ័ត្ន ប្រធានការិយាល័យវិភាគសេដ្ឋកិច្ចជាតិ នៃនាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច ជាជំនួយការ

៣- លោក ចៅ សុខមុនី ប្រធានការិយាល័យធនាគារពិភពលោកនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ជាជំនួយការ

៤- លោក ម៉ៅ បុណ្ណខេត្ត អនុប្រធានការិយាល័យគ្រប់គ្រងថវិការបស់ខេត្ត ក្រុង នៃនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ជាជំនួយការ ។

**ប្រការ ៣ :** លេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ សង្កាត់ មានភារៈកិច្ចដូចខាងក្រោម ៖

- ផ្តល់រាល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ សង្កាត់
- រៀបចំរាល់ការងារដែលក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ សង្កាត់ ត្រូវប្រជុំពិភាក្សាអនុម័ត
- រៀបចំ សំរបសំរួល និង ធ្វើកំណត់ហេតុរាល់កិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ សង្កាត់
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សកម្មភាពនៃកិច្ចប្រតិបត្តិការមូលនិធិ ឃុំ សង្កាត់ ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ។

**ប្រការ ៤ :** មន្ត្រីជំនួយការត្រូវទៅបំពេញការងារនៅលេខាធិការដ្ឋាន តាមការអញ្ជើញរបស់លេខាធិការ នៅពេលមានតំរូវការចាំបាច់ ។

**ប្រការ ៥ :** ប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ និងប្រធាននាយកដ្ឋានវិភាគនិងព្យាករណ៍សេដ្ឋកិច្ច ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២

**គាត ឈន់**

ចំលងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ជាពត៌មាន"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ